

## ប្រសិទ្ធភាពរបស់វ៉ាក់សាំង

- វ៉ាក់សាំងធ្វើឱ្យប្រព័ន្ធការពាររាងកាយស្គាល់ និងទប់ស្កាត់វីរុសនៅពេលដែលវាឆ្លងចូលក្នុងខ្លួនមនុស្ស។ វ៉ាក់សាំងមានប្រវត្តិជោគជ័យយូរអង្វែងមកហើយ គេបានផលិត និងប្រើដំបូងតាំងពី ២២៥ឆ្នាំមកម្ល៉េះ។ តាមរយៈប្រវត្តិសាស្ត្រ មនុស្សបានបង្កើតវ៉ាក់សាំងដោយជោគជ័យ សម្រាប់ប្រឆាំងនឹងជំងឺដែលអាចបណ្តាលឱ្យពិការភាពអស់មួយជីវិត ឬ ស្លាប់ជាច្រើន រួមទាំងជំងឺរលាកស្រោមខួរ តេតាណុស កញ្ជ្រឹល គ្រុនស្វិតដៃជើង ហើយឥឡូវនេះគឺជំងឺកូវីដ-១៩។
- វ៉ាក់សាំងកូវីដ-១៩ គឺជាថ្នាំបង្ការថ្មីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បន្ថែមពីលើការអនុវត្តន៍នូវវិធានការការពារដូចជា៖ ពាក់ម៉ាស់ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាតពីអ្នកដទៃយ៉ាងតិច ១,៥ម៉ែត្រ។



## សូមចងចាំ

សូមចាំថាវ៉ាក់សាំងគឺជាថ្នាំបង្ការដ៏សំខាន់ រួមជាមួយនឹងវិធានការបង្ការផ្សេងទៀត ក្នុងការការពារខ្លួនអ្នក គ្រួសាររបស់អ្នក និងសហគមន៍ ជាពិសេសជួយសង្គ្រោះជីវិតយើងពីជំងឺកូវីដ-១៩។ គ្រប់វ៉ាក់សាំងដែលអនុញ្ញាតឱ្យចាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈគឺមានសុវត្ថិភាព និងប្រសិទ្ធភាព។

**សូមចុះឈ្មោះ និង ទៅចាក់វ៉ាក់សាំង កូវីដ-១៩ ប្រសិនបើដល់វេនលោកអ្នក។**



ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខ
**១១៥ ដោយឥតគិតថ្លៃ។**

# អ្វីខ្លះដែលខ្ញុំត្រូវដឹងអំពីវ៉ាក់សាំងកូវីដ-១៩?



# សុវត្ថិភាពរបស់វ៉ាក់សាំង

- ការផលិតវ៉ាក់សាំងកូវីដ-១៩ ត្រូវបានអនុវត្តដូចនឹងការផលិតវ៉ាក់សាំងដទៃទៀតដែរ។ វ៉ាក់សាំងគឺត្រូវការឆ្លងកាត់ជាច្រើនដំណាក់កាលក្នុងការផលិត និងតេស្តសាកល្បង។ ជាទូទៅ ការធ្វើតេស្តគ្លីនិកមានចំនួន ៣លើក ហើយការធ្វើតេស្តលើកទី៣ គឺតែងតែធ្វើលើមនុស្សប្រមាណជាមួយម៉ឺននាក់។
- ក្រសួងសុខាភិបាលបានចេញសេចក្តីប្រកាសអនុញ្ញាតឱ្យប្រើប្រាស់វ៉ាក់សាំងក្នុងគ្រាអាសន្នបន្ទាប់ពីបានពិនិត្យលើទិន្នន័យដែលមានពីអាជ្ញាធរបទប្បញ្ញត្តិនៃប្រទេសផ្សេងទៅលើសុវត្ថិភាព និងប្រសិទ្ធភាពរបស់វ៉ាក់សាំងនោះ ឬ បន្ទាប់ពីវ៉ាក់សាំងនោះបានដាក់ បញ្ចូលទៅក្នុងបញ្ជីប្រើប្រាស់ក្នុងគ្រាអាសន្នរបស់អង្គការសុខភាពពិភពលោក (Emergency Use List - EUL)។ នៅពេលដែលវ៉ាក់សាំងដាក់ឱ្យប្រើប្រាស់នោះនឹងមានការតាមដានដើម្បីឱ្យប្រាកដថា មានសុវត្ថិភាពដល់អ្នកចាក់វ៉ាក់សាំង។








# ការចុះឈ្មោះ និងចាក់វ៉ាក់សាំង

- ការចុះឈ្មោះចាក់វ៉ាក់សាំងតាមអនឡាញ នឹងដាក់ឱ្យប្រើប្រាស់ក្នុងពេលឆាប់ៗនេះ។ ព័ត៌មានលម្អិត និងសេចក្តីណែនាំក្នុងការចុះឈ្មោះ នឹងជូនដំណឹងទៅសាធារណជនក្នុងពេលឆាប់ៗនេះ។
- វ៉ាក់សាំងកូវីដ-១៩ នឹងផ្តល់នៅមន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាព។ សូមរង់ចាំស្តាប់ការជូនដំណឹងនៅក្នុងតំបន់របស់អ្នក។





# ក្រុមគោលដៅដែលត្រូវទទួលវ៉ាក់សាំង

យោងតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ដោយបរិមាណនៃវ៉ាក់សាំងកូវីដ-១៩ មានកំណត់ និងតាមស្ថានភាពរបស់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចឱ្យអាទិភាពទៅលើ៖

- ក្រុមអាទិភាព ដែលរួមមានបុគ្គលិកសុខាភិបាល យោធា និងនគរបាលជួរមុខ មន្ត្រីរដ្ឋាភិបាល ជនបង្គោលសហគមន៍ និងក្រុមទ្រទ្រង់សុខភាពភូមិ។
- ក្រុមងាយរងគ្រោះ ដែលរួមមានមនុស្សចាស់អាយុចាប់ពី៦៥ឆ្នាំឡើង និងមនុស្សពេញវ័យដែលមានជំងឺរ៉ាំរ៉ៃ។
- ក្រុមកម្មករ
    - អ្នករត់ម៉ូតូឌុប ម៉ូតូកង់បី ស៊ីក្លូ និងផ្សេងៗ
    - កម្មករប្រមូលសំរាម និងផ្សេងៗ
    - កម្មកររោងចក្រ និងការដ្ឋានសាងសង់
- ក្នុងពេលបច្ចុប្បន្ននេះ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ១៦ឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យចាក់វ៉ាក់សាំងនោះទេ ដោយសារនៅមិនទាន់មានទិន្នន័យគ្រប់គ្រាន់ពីលទ្ធផលនៃការធ្វើតេស្តនៅឡើយ។